National Tourism of Polic with cover on 19.08.2010:Layout 1 19/08/2010 10:34 Page 1

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាល

# គោលនយោបាយជាតិ លើវិស័យទេសចរណ៍នៅក្នុង ព្រះរាជាណាចក្រកម្ពុជា

អនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ

នាថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៨



CAMBODIA
*Kingdom of Wonder*

# កម្ពុជា: ព្រះរាជាណាចក្រអច្ឆរិយៈ

## ចូលរួមចលនាប្រឡងប្រណាំង

- ទីក្រុងស្អាត
- រមណីយដ្ឋានស្អាត
- សេវាល្អ

ក្រសួងទេសចរណ៍
ដីឡូត៍លេខ ៣A ផ្លូវ ១៦៩ សង្កាត់ វាលវង់ ខណ្ឌ ៧ មករា
រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥ ២៣) ២១៣ ៧៤១ / ទូរសារ : (៨៥៥ ២៣) ២២០ ៧០៤
អ៊ីម៉ែល : admin@mot.gov.kh / វិបសាយ : www.mot.gov.kh



National Tourism of Polic with cover on 19.08.2010:Layout 1 19/08/2010 10:34 Page 1

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**........................................................................ ០៣

**ជំពូកទី ១. ចក្ខុវិស័យ**.................................................................. ០៤

**ជំពូកទី ២. គោលការណ៍គ្រឹះជាមូលដ្ឋាន**........................................ ០៥

២.១. ទេសចរណ៍វប្បធម៌ និងធម្មជាតិ........................................ ០៥

២.២. គោលដៅទេសចរណ៍.................................................. ០៦

២.៣. សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពទេសចរណ៍..... ០៧

២.៤. តុល្យភាពរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងការអភិរក្សសម្បត្តិ វប្បធម៌ និងធនធានធម្មជាតិ........................................... ០៧

២.៥. ទម្រង់ដែលជះឥទ្ធិពលជាអវិជ្ជមាននៅវិស័យទេសចរណ៍.......... ០៨

**ជំពូកទី ៣. គោលនយោបាយអភិវឌ្ឍ និងគ្រប់គ្រងវិស័យទេសចរណ៍**

...................................................................................... ០៨

៣.១. ការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព............. ០៨

៣.១.១. អត្ថន័យ ៥យ៉ាង នៃការអភិវឌ្ឍទេសចរណ៍ប្រកប ដោយនិរន្តរភាព.............................................. ០៨

៣.១.២. ការធ្វើផែនការអភិវឌ្ឍសម្រាប់វិស័យទេសចរណ៍..... ០៩

៣.១.៣. ទម្រង់ផ្សេងៗនៃវិស័យទេសចរណ៍........................ ០៩

- កសិទេសចរណ៍ និងទំនាក់ទំនងទៅនឹងវិស័យ កសិកម្ម...................................................... ០៩
- កីឡាទេសចរណ៍.......................................... ០៩
- ទេសចរណ៍សហគមន៍................................... ១០
- ទេសចរណ៍ផ្សេងទៀត.................................. ១០

៣.១.៤. ប្រព័ន្ធច្បាប់.................................................... ១០

៣.១.៥. ការកាត់បន្ថយភាពក្រីក្រ.................................. ១០

៣.២. កិច្ចសហប្រតិបត្តិការជាមួយវិស័យដទៃទៀត........................ ១១
៣.៣. ការអភិវឌ្ឍធនធានមនុស្ស................................................ ១២
៣.៣.១. ការអប់រំ និងការបណ្តុះបណ្តាល........................... ១២
៣.៣.២. ការសិក្សាស្រាវជ្រាវ និងស្ថិតិទេសចរណ៍................ ១៣
៣.៣.៣. កម្មវិធីផ្សព្វផ្សាយយល់ដឹងសាធារណៈ................... ១៣
៣.៣.៤. ការកសាងសមត្ថភាពរបស់ក្រសួងទេសចរណ៍.......... ១៣
៣.៤. ផ្នែកឯកជន.................................................................... ១៤
៣.៤.១. ការទ្រទ្រង់ចំពោះផ្នែកឯកជន............................. ១៤
៣.៤.២. ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍............ ១៤
៣.៤.៣. ការធ្វើអាជីវកម្មទេសចរណ៍................................ ១៥
៣.៤.៤. ក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈ................. ១៥
៣.៥. ការសម្រួលការធ្វើដំណើរ និងទំនាក់ទំនងអន្តរជាតិ................ ១៥
៣.៥.១. ការសម្រួលការធ្វើដំណើរ និងបែបបទចេញ ចូល នៃទេសចរ...................................................... ១៥
៣.៥.២. ទំនាក់ទំនងអាស៊ាន និងកិច្ចសហប្រតិបត្តិការ អន្តរជាតិ........................................................ ១៥

**សេចក្តីសន្និដ្ឋាន**.................................................................................. ១៦

National Tourism of Polic with cover on 19.08.2010:Layout 1 19/08/2010 10:34 Page 3

# សេចក្តីផ្តើម

កម្ពុជាបាន និងកំពុងបោះជំហានយ៉ាងស្វាហាប់ ដោយប្រកាន់យកនូវរបបសេដ្ឋកិច្ចទីផ្សារ ស្របពេលដែលពិភពលោកមានការផ្លាស់ប្តូរ និងរីកចម្រើនយ៉ាងខ្លាំងលើវិស័យទេសចរណ៍ ។ វិស័យទេសចរណ៍ ដែលមានលក្ខណៈជាប្រព័ន្ធ កំពុងមាននិន្នាការវិវឌ្ឍ និងរីកចម្រើនយ៉ាងឆាប់រហ័ស ហើយត្រូវបានទទួលស្គាល់ថា ជាកម្លាំងចលករមួយដ៏មានឥទ្ធិពលក្នុងការជំរុញល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។ វិស័យទេសចរណ៍ ជាប្រភពដ៏សំខាន់ក្នុងការផ្តល់ការងារ ផ្តល់កាលានុវត្តភាព សម្រាប់ប្រជាជនរាប់សិបលាននាក់ក្នុងពិភពលោក ទទួលបាននូវប្រាក់ចំណូលបន្ថែម ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងរួមចំណែកកាត់បន្ថយភាពក្រីក្រ ។

កម្ពុជា ជាប្រទេសមួយដែលសម្បូរកេរដំណែលសម្បត្តិវប្បធម៌ ប្រវត្តិសាស្ត្រ ធម្មជាតិដ៏ចិញ្ចាចចិញ្ចែងតាំងពីបរមបុរាណ ដែលក្នុងនោះ ក៏បានស្តែងចេញនូវវីរភាពដ៏អស្ចារ្យរបស់បុព្វបុរសខ្មែរក្នុងការសាងសង់នូវប្រាង្គប្រាសាទបុរាណ ទីសក្ការៈបូជា វត្តអារាមនានាជាអាទិ៍ ប្រាសាទអង្គរវត្ត និងប្រាង្គប្រាសាទរាប់ពាន់ផ្សេងទៀតនៅពាសពេញផ្ទៃប្រទេស ។

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល វិស័យទេសចរណ៍កម្ពុជា បាននិងកំពុងរីកលូតលាស់គួរឱ្យកត់សម្គាល់ ក្នុងអត្រាកំណើនមធ្យមប្រចាំឆ្នាំពី ២៥-៣០ ភាគរយចន្លោះ ពីឆ្នាំ ១៩៩៣ - ២០០៦ ។ ដោយឡែក ឆ្នាំ ២០០៧ យើងទទួលបានទេសចរអន្តរជាតិចំនួន ២.០១៥.១២៨ នាក់ កើនឡើង ១៨,៥៣ ភាគរយ និងផ្តល់ឱកាសការងារជូនប្រជាពលរដ្ឋដោយផ្ទាល់បាន ៣០ ម៉ឺននាក់ និងការងារដោយប្រយោល រាប់ម៉ឺននាក់បន្ថែមទៀត ។ ចំណូលទេសចរណ៍ បាននិងកំពុងរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដោយរួមចំណែកប្រមាណជាង ១០ ភាគរយ នៃផលិតផលក្នុងស្រុកសរុប ។

ការអភិវឌ្ឍទេសចរណ៍ ត្រូវមាននិរន្តរភាពដោយត្រូវធានាឱ្យបាននូវផលប្រយោជន៍ជាតិ ផលប្រយោជន៍ប្រជាពលរដ្ឋក្នុងស្រុក និងផ្នែកពាក់ព័ន្ធ ព្រមទាំងទប់ស្កាត់ផលប៉ះពាល់ជាអវិជ្ជមានមកលើសេដ្ឋកិច្ចសង្គម វប្បធម៌ និងបរិស្ថាន ។ ដើម្បីសម្រេចគោលដៅនេះ គឺមានកត្តាជាច្រើនដែលត្រូវរៀបចំ និងអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធផ្នែកសាធារណៈ ផ្នែកឯកជន ប្រជាពលរដ្ឋ និងដៃគូអភិវឌ្ឍ ។ គន្លឹះដ៏សំខាន់មួយដែលមិនអាចខ្វះបាន គឺគោលនយោបាយជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងអភិវឌ្ឍវិស័យទេសចរណ៍ ។ គោលនយោបាយនេះ គឺជាត្រីវិស័យ បង្ហាញទិសក្នុងការអនុវត្ត និងជាឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការគាំទ្រ និងជំរុញតម្រង់ទិសការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព ។

## ជំពូកទី១. ចក្ខុវិស័យ

១.១. **វិស័យទេសចរណ៍កម្ពុជា ជាទេសចរណ៍វប្បធម៌ និងធម្មជាតិ** ដែលនឹងបង្កើតបាននូវផលជាវិជ្ជមាន ស្របទៅតាមនិន្នាការអភិវឌ្ឍវិស័យទេសចរណ៍តំបន់ និងពិភពលោកនាពេលបច្ចុប្បន្ន និងអនាគត ។

១.២. រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព ដើម្បីជាប្រយោជន៍របស់ជាតិ ជាឧបករណ៍មួយយ៉ាងសំខាន់ក្នុងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការរួមចំណែកកាត់បន្ថយភាពក្រីក្រ ។ ការអនុវត្តតាមចក្ខុវិស័យនៃគោលនយោបាយនេះ គឺត្រូវប្រើប្រាស់ឱ្យអស់លទ្ធភាពនូវសក្តានុពលដែលមានប្រកបដោយការទទួលខុសត្រូវ ត្រូវយកចិត្តទុកដាក់គោរពដល់តម្លៃវប្បធម៌ សង្គមជាតិទាំងអស់នោះ និងផ្តល់ជូនដល់ទេសចរទាំងជាតិ និងអន្តរជាតិនូវបទពិសោធនៃការទស្សនាកំសាន្ត ប្រកបដោយគុណភាពនូវតម្លៃភាពទោលនៃសក្តានុពលទាក់ទាញទេសចរណ៍នៅកម្ពុជា ។

១.៣. ការទាក់ទាញទេសចរ និងយុទ្ធសាស្ត្រអភិវឌ្ឍ ត្រូវផ្តោតទៅលើរមណីយដ្ឋានបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ ប្រពៃណី ភាពញញឹមរាក់ទាក់ព្រមទាំងភាពសម្បូរបែប នៃទេសភាពធម្មជាតិដ៏ស្រស់បំព្រងនៅលើទឹកដីកម្ពុជា ។ ដោយឡែក ការខិតខំប្រឹងប្រែងដ៏មានសារៈសំខាន់នានា នឹងត្រូវដាក់បញ្ចូលរួមគ្នា សំដៅធ្វើការឆ្លុះបញ្ចាំងនូវទិដ្ឋភាពប្លែកៗគ្នានៃព្រះរាជាណាចក្រកម្ពុជានៅលើឆាកអន្តរជាតិ ពិសេសការទាក់ទាញនៃភាពទោលរបស់**ឧទ្យានបេតិកភណ្ឌអង្គរ រមណីយដ្ឋានសក្ការៈនៃប្រាសាទព្រះវិហារ** បន្ទាប់មកមានសត្វផ្សោតទន្លេមេគង្គ តំបន់ជីវចម្រុះបឹងទន្លេសាប តំបន់ទាក់ទាញបែបធម្មជាតិតំបន់ឆ្នេរ និងតំបន់អេកូទេសចរណ៍នៅភូមិភាគឦសាន្ត ភូមិភាគនិរតី និងបឹងទន្លេសាប ។

National Tourism of Polic with cover on 19.08.2010:Layout 1 19/08/2010 10:34 Page 5

# ជំពូកទី២. គោលការណ៍គ្រឹះជាមូលដ្ឋាន

## ២.១. ទេសចរណ៍វប្បធម៌ និងធម្មជាតិ

២.១.១. ទេសចរណ៍វប្បធម៌ និងធម្មជាតិ មានទិសដៅច្បាស់លាស់ ដែលត្រូវសម្រេចឱ្យបានក្នុងការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព។ ទិសដៅទាំងនេះ គឺការអភិរក្ស ថែរក្សា ការពារ ការប្រើប្រាស់សម្បត្តិវប្បធម៌ និងធនធានធម្មជាតិប្រកបដោយស្មារតីទទួលខុសត្រូវ និងការបង្កើនផលប្រយោជន៍ពីប្រភពទាំងនេះ ព្រមទាំងធ្វើឱ្យអ្នកពាក់ព័ន្ធទទួលផលប្រកបដោយសមធម៌។

២.១.២. ទេសចរណ៍វប្បធម៌ និងធម្មជាតិ មិនគ្រាន់តែទាក់ទិនដល់ការគ្រប់គ្រង និងការការពារតម្លៃសម្បត្តិវប្បធម៌ និងធនធានធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែគឺថែមទាំងទាក់ទិននឹងការស្វែងយល់ពីផលប៉ះពាល់នៃទេសចរណ៍មកលើសេដ្ឋកិច្ច និងសង្គម ព្រមទាំងការសម្រេចឱ្យបាននូវផលចំណេញសេដ្ឋកិច្ច ការផ្គត់ផ្គង់ធនធានហិរញ្ញវត្ថុសម្រាប់ការការពារ រួមទាំងការផ្សព្វផ្សាយ និងរកទីផ្សារផងដែរ។

២.១.៣. ដើម្បីធានាបាននូវការអភិវឌ្ឍ និងគ្រប់គ្រងទេសចរណ៍វប្បធម៌ និងធម្មជាតិឱ្យបានជោគជ័យកត្តាសំខាន់ៗជាមូលដ្ឋានមួយចំនួនត្រូវយកចិត្តទុកដាក់រួមមាន :

- ធ្វើការចុះបញ្ជីសារពើភណ្ឌ និងវាយតម្លៃសម្បត្តិវប្បធម៌ និងធនធានធម្មជាតិរបស់ប្រទេស ដើម្បីកំណត់ធនធានសំខាន់ៗដែលត្រូវអភិវឌ្ឍសម្រាប់វិស័យទេសចរណ៍
- រៀបចំធ្វើផែនការ និងការពារសម្បត្តិវប្បធម៌ និងធនធានធម្មជាតិទាំងនេះ ផ្តល់ឱកាសដល់សហគមន៍ ព្រមទាំងភាគីពាក់ព័ន្ធទាំងអស់ បានចូលរួមធ្វើផែនការ និងគ្រប់គ្រងឱ្យបានទូលំទូលាយសម្រាប់សកម្មភាពអភិវឌ្ឍទេសចរណ៍ប្រកបដោយគុណភាព និងនិរន្តរភាព
- ត្រូវវាយតម្លៃ ពីផលប៉ះពាល់នៃការអភិវឌ្ឍទេសចរណ៍ទៅលើសម្បត្តិ និងធនធានទាំងនេះ និងត្រូវផ្តល់នូវជំនួយខាងវិជ្ជាជីវៈ និងការអប់រំដើម្បីផ្តល់នូវការកសាងសមត្ថភាពខាងបច្ចេកវិទ្យាអភិរក្ស និងជួយធ្វើឱ្យសម្បត្តិ និងធនធានទាំងនេះស្ថិតស្ថេរតទៅទៀត។

## ២.២. គោលដៅទេសចរណ៍

២.២.១. ការអភិវឌ្ឍទេសចរណ៍ ទាមទារឱ្យមានយុទ្ធសាស្ត្រគ្រប់គ្រង គោលដៅទាក់ទាញទេសចរណ៍។ សម្រាប់តំបន់គោលដៅទាក់ទាញទេសចរណ៍អាទិភាពចំនួន ៤ : **ភ្នំពេញ និងតំបន់ជុំវិញ សៀមរាបអង្គរ និងតំបន់ជុំវិញ តំបន់ឆ្នេរ និងតំបន់អេកូទេសចរណ៍ នៅភូមិភាគឦសាន្ត ភូមិភាគនិរតី និងបឹងទន្លេសាប** ដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកធ្វើជាប៉ូលអាទិភាពសម្រាប់ការអភិវឌ្ឍ ដើម្បីទាក់ទាញទេសចរជាតិ និងអន្តរជាតិ ក្រសួងទេសចរណ៍ សហការជាមួយគ្រប់ស្ថាប័ន និងភាគីពាក់ព័ន្ធ រៀបចំផែនការមេ និងយុទ្ធសាស្ត្រអភិវឌ្ឍមួយប្រកបដោយប្រសិទ្ធភាព និរន្តរភាព ធានាបង្កាទប់ស្កាត់ផលប៉ះពាល់ជាអវិជ្ជមានទៅលើសម្បត្តិវប្បធម៌ ប្រពៃណី ធនធានធម្មជាតិ ក៏ដូចជាបាតុភាពអសកម្មនានា។

២.២.២. តំបន់អាទិភាពទាំងនេះ ត្រូវផ្សារភ្ជាប់គ្នាដោយមធ្យោបាយដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធល្អបង្គួរ និងត្រូវតែធានាបាននូវការអភិវឌ្ឍ និងគ្រប់គ្រងទៅកាន់តំបន់ដទៃៗទៀត ព្រមទាំងត្រូវមានគោលនយោបាយជាតិសមស្របដោយ :

- រៀបចំបង្កើតឱ្យមានប្រព័ន្ធដឹកជញ្ជូនផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ប្រកបដោយសុវត្ថិភាព ផាសុកភាព
- ត្រូវយកចិត្តទុកដាក់ ដល់កិច្ចអភិវឌ្ឍរៀបចំទីក្រុង ទីប្រជុំជន តំបន់គោលដៅទាក់ទាញទេសចរណ៍ ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ រៀបចំគ្រប់គ្រងសេវាកម្មទេសចរណ៍ អភិវឌ្ឍមណ្ឌលកំសាន្តរមណីយដ្ឋានទេសចរណ៍ គ្រប់រូបភាពបន្ថែមទៀត ដើម្បីទាក់ទាញទេសចរឱ្យបានច្រើន ស្នាក់នៅបានយូរ និងមកទស្សនាច្រើនដង
- ជំរុញកិច្ចអភិវឌ្ឍសហគមន៍ ដោយធ្វើឱ្យអ្នកពាក់ព័ន្ធទទួលបានផលប្រយោជន៍ពីទេសចរណ៍ប្រកបដោយសមធម៌
- ជំរុញការបណ្តុះបណ្តាលធនធានមនុស្ស និងអភិវឌ្ឍផលិតផលទេសចរណ៍ជាពិសេស ការកសាងតំបន់ខ្សែក្រវាត់បៃតងឱ្យសម្បូរបែប ឈានទៅជំនួសការនាំចូលពីបរទេស។

National Tourism of Polic with cover on 19.08.2010:Layout 1 19/08/2010 10:34 Page 7

## ២.៣. សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពទេសចរណ៍

២.៣.១. ទេសចរណ៍ជាប្រភពមួយ ក្នុងការរកចំណូលជួយដល់សេដ្ឋកិច្ចជាតិ និងសង្គម ។ ដើម្បីធ្វើឱ្យទេសចរមានទំនុកចិត្តក្នុងការធ្វើដំណើរមកកាន់ព្រះរាជាណាចក្រកម្ពុជា និងចូលរួមទស្សនាកំសាន្ត ដោយសប្បាយរីករាយ ការរក្សាការពារបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់គ្រប់គ្រាន់ជូនដល់ទេសចរ ត្រូវចាត់ទុកជាអាទិភាពចម្បង ។

២.៣.២. សមត្ថកិច្ចពាក់ព័ន្ធ ត្រូវបង្កើនកិច្ចសហការដើម្បីធានាបង្កាទប់ស្កាត់បង្ក្រាបនូវបទល្មើស ការរំខានផ្សេងៗដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់របស់ទេសចរ និងរិះរកគ្រប់វិធីទ្រទ្រង់ដល់អង្គភាពនគរបាលទេសចរណ៍ ឱ្យអនុវត្តការងារមានប្រសិទ្ធភាពក្នុងការធានាការពារសន្តិសុខ សុវត្ថិភាពជូនទេសចរ ។

២.៣.៣. ត្រូវមានគិលានដ្ឋាន មណ្ឌលសុខភាព មន្ទីរពេទ្យ ក្រុមសង្គ្រោះ រថយន្តសង្គ្រោះបន្ទាន់ ប្រចាំការនៅតាមរមណីយដ្ឋាន គោលដៅទាក់ទាញទេសចរណ៍សំខាន់ៗ និងបំពាក់ទៅដោយឧបករណ៍សម្ភារៈ ប្រព័ន្ធការពារថែរក្សាអនាម័យ និងសុខភាពគ្រប់គ្រាន់សម្រាប់ទេសចរ ។

២.៣.៤. ត្រូវរៀបចំផែនការ បទដ្ឋានគតិយុត្ត យន្តការ និងយុទ្ធនាការចាំបាច់ផ្សេងៗទៀត ដើម្បីធានារក្សាសន្តិសុខ សុវត្ថិភាពទេសចរ ។

## ២.៤. តុល្យភាពរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងការអភិរក្សសម្បត្តិវប្បធម៌ និងធនធានធម្មជាតិ

ទិសដៅដ៏ចម្បង សម្រាប់ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាពនៅកម្ពុជា គឺត្រូវតែសម្រេចឱ្យបាននូវតុល្យភាពមួយ ដែលមានប្រសិទ្ធភាពរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងការអភិរក្សសម្បត្តិវប្បធម៌ និងធនធានធម្មជាតិ ដោយឈរលើការគោរពតម្លៃនៃសម្បត្តិ និងធនធានទាំងនេះ និងដោយមានការចូលរួមរបស់ភាគីពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន ។ កិច្ចអភិវឌ្ឍទេសចរណ៍ត្រូវរៀបចំឱ្យមានអត្ថប្រយោជន៍ជាអតិបរមាដល់សេដ្ឋកិច្ចសង្គម វប្បធម៌ និងបរិស្ថាន ទន្ទឹមគ្នានឹងការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន ដោយធានាឱ្យមានតុល្យភាពមួយរវាងការខាតបង់នឹងអត្ថប្រយោជន៍ និងរវាងតម្រូវការនឹងការផ្គត់ផ្គង់ ពោលគឺការអភិរក្ស និងការអភិវឌ្ឍត្រូវដើរទន្ទឹមគ្នា ។

### ២.៥. ទម្រង់ដែលជះឥទ្ធិពលជាអវិជ្ជមាននៃវិស័យទេសចរណ៍

រាជរដ្ឋាភិបាលកម្ពុជា ប្រឆាំងដាច់ខាតចំពោះទេសចរណ៍ផ្លូវភេទលើកុមារ និងទម្រង់ផ្សេងទៀត នៃការកេងប្រវញ្ចធ្វើអាជីវកម្មលើកុមារ និងស្ត្រី ព្រមទាំងប្រភេទអសីលធម៌ផ្សេងៗទៀត និងបញ្ឈប់រាល់ទម្រង់ទេសចរណ៍ដែលទាក់ទងដល់គ្រឿងញៀន ឬសារធាតុផ្សេងទៀតដែលត្រូវបានហាមឃាត់ និងទម្រង់ទាំងឡាយដែលនាំឱ្យមានជំងឺឆ្លងរាលដាលផ្សេងៗ ជាពិសេសជំងឺអេដស៍ ។

## ជំពូកទី៣. គោលនយោបាយអភិវឌ្ឍ និងគ្រប់គ្រងវិស័យទេសចរណ៍

### ៣.១. ការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព

### ៣.១.១. អត្ថន័យ ៥ យ៉ាង នៃការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព

ការអភិវឌ្ឍទេសចណ៍ប្រកបដោយនិរន្តរភាព ត្រូវបញ្ចូលខ្លឹមសារជាមូលដ្ឋានគ្រឹះ ៥ យ៉ាងរួមមាន :

- អភិរក្ស ការពារ និងកែលំអឱ្យបានសមស្រប នូវទីកន្លែងដែលមានសម្បត្តិវប្បធម៌ និងធនធានធម្មជាតិ ដែលជាមូលដ្ឋានគ្រឹះសម្រាប់វិស័យទេសចរណ៍
- ជំរុញកិច្ចអភិវឌ្ឍទេសចរណ៍ និងធ្វើឱ្យអ្នកពាក់ព័ន្ធទទួលផលពីទេសចរណ៍ប្រកបដោយសមធម៌ បង្កើនអត្ថប្រយោជន៍ កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃវិស័យទេសចរណ៍ មកលើសេដ្ឋកិច្ចសង្គម វប្បធម៌ បរិស្ថាន
- ធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ យកចិត្តទុកដាក់ដោះស្រាយតម្រូវការ និងគោរពនូវតម្លៃរបស់សហគមន៍
- ចែករំលែកបទពិសោធ ប្រកបដោយគុណភាពខ្ពស់ ដើម្បីបង្កើននូវកម្រិតនៃការពេញចិត្តរបស់ទេសចរ ក្នុងការទស្សនាកំសាន្ត និងទាក់ទាញឱ្យមានការផ្សព្វផ្សាយបន្ត ព្រមទាំងការវិលត្រឡប់មកវិញជាថ្មីទៀត
- ថែរក្សានូវគុណភាពនៃសម្បត្តិ និងធនធានទាំងអស់ ទៅតាមវិធីដែល

អាចទ្រទ្រង់ផលិតភាពយូរអង្វែង និងការអភិវឌ្ឍ ដែលធ្វើឱ្យមាននិរន្តរភាពសម្រាប់មនុស្សជំនាន់ក្រោយ ។

### ៣.១.២. ការធ្វើផែនការអភិវឌ្ឍសម្រាប់វិស័យទេសចរណ៍

ក្រសួងទេសចរណ៍ មានភារកិច្ចទទួលខុសត្រូវ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំផែនការទេសចរណ៍សម្រាប់ព្រះរាជាណាចក្រកម្ពុជាក្នុងកម្រិត និងទៅតាមផ្នែកផ្សេងៗគ្នា ទាំងនេះ រាប់បញ្ចូលទាំងផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ ផែនការមេ យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់រាជធានី ខេត្ត ក្រុង ផែនការយុទ្ធសាស្ត្រអេកូទេសចរណ៍ ផែនការយុទ្ធសាស្ត្រតំបន់ឆ្នេរ ផែនការកសិទេសចរណ៍ ផែនការទេសចរណ៍សហគមន៍ និងទាំងផែនការទេសចរណ៍កាត់បន្ថយភាពក្រីក្រ ។ រាជរដ្ឋាភិបាលកម្ពុជា សហការយ៉ាងជិតស្និទ្ធជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិ ដោយអនុវត្តនូវកិច្ចសហប្រតិបត្តិការក្នុងការធ្វើផែនការទេសចរណ៍ និងជំរុញការអនុវត្តប្រកបដោយនិរន្តរភាព ។

### ៣.១.៣. ទម្រង់ផ្សេងៗនៃវិស័យទេសចរណ៍

**កសិទេសចរណ៍ និងទំនាក់ទំនងទៅនឹងវិស័យកសិកម្ម**

ដោយឈរលើសារៈសំខាន់ដ៏ឧត្តុង្គឧត្តម នៃវិស័យកសិកម្មចំពោះជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសនៅតាមសហគមន៍ និងតាមជនបទ ការលើកស្ទួយផ្នែកកសិទេសចរណ៍ និងការដាក់បញ្ចូលផ្នែកនេះ ទៅក្នុងផែនការអភិវឌ្ឍទេសចរណ៍ គឺជាប្រការមួយដ៏ចាំបាច់បំផុត ។

**កីឡាទេសចរណ៍**

សក្តានុពលនៃកីឡាទេសចរណ៍ បានផ្តល់នូវកាលានុវត្តភាពមួយសម្រាប់ប្រភេទទេសចរណ៍កម្ពុជា ធ្វើឱ្យផលិតផលទេសចរណ៍សម្បូរបែបនិងប្លែកៗ ព្រោះកីឡាមិនត្រឹមតែនាំមកនូវសុខភាពប៉ុណ្ណោះទេ តែថែមទាំងនាំមកនូវមិត្តភាពសាមគ្គីភាព កិច្ចសហប្រតិបត្តិការប្រកបដោយភាពរីកចម្រើន ព្រមទាំងការផ្លាស់ប្តូរប្រពៃណី ទំនៀមទម្លាប់ផងដែរ ។

National Tourism of Polic with cover on 19.08.2010:Layout 1 19/08/2010 10:34 Page 10

**ទេសចរណ៍សហគមន៍**

ដើម្បីជាការទ្រទ្រង់ដល់មូលដ្ឋាន និងសហគមន៍ ជាពិសេសជនជាតិភាគតិចក្នុងបរិបទនៃការកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលកម្ពុជា ក្នុងភាពជាដៃគូជាមួយស្ថាប័នជាតិ អន្តរជាតិ ផ្នែកឯកជន ដែលមានការពាក់ព័ន្ធ ត្រូវផ្តល់ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម នូវការប្រឹក្សាយោបល់ខាងផ្នែកពាណិជ្ជកម្ម សេវាកម្ម ផែនការដែលទាក់ទងទៅនឹងប្រភពហិរញ្ញវត្ថុ ការសិក្សាទីផ្សារ និងការបណ្តុះបណ្តាល ។

**ទេសចរណ៍ផ្សេងទៀត**

ក្រៅពីបណ្តាទម្រង់ខាងលើ ក្រសួងទេសចរណ៍ ត្រូវយកចិត្តទុកដាក់សិក្សាស្រាវជ្រាវ បង្កើត និងជំរុញអភិវឌ្ឍនូវទម្រង់ផ្សេងៗទៀតដូចជា : **អេកូទេសចរណ៍ ទេសចរណ៍បែបកំសាន្តសប្បាយ និងសិក្សាស្រាវជ្រាវ ទេសចរណ៍បែបចូលរួមកិច្ចប្រជុំ តាំងពិព័រណ៍ ទេសចរណ៍បែបព្យាបាលជំងឺ ទេសចរណ៍បែបសាសនា** ។ល ។

## ៣.១.៤. ប្រព័ន្ធច្បាប់

ក្រសួងទេសចរណ៍ ត្រូវរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត រួមទាំងនីតិវិធីនានា ដែលពាក់ព័ន្ធដល់ការគ្រប់គ្រង ការបែងចែកធនធាន ការវិនិយោគ ការធ្វើអាជីវកម្ម ការថែរក្សា ការអភិវឌ្ឍ និងគ្រប់គ្រងវិស័យទេសចរណ៍ប្រកបដោយប្រសិទ្ធភាពខ្ពស់ និរន្តរភាព និងរក្សាបាននូវសម្បត្តិវប្បធម៌ ធនធានធម្មជាតិ ។ ក្រសួងទេសចរណ៍ ត្រូវកំណត់នូវតួនាទីភារកិច្ចទទួលខុសត្រូវរបស់អង្គភាពចំណុះក្នុងការគ្រប់គ្រង និងការអភិវឌ្ឍទេសចរណ៍ឱ្យបានល្អប្រសើរនៅថ្នាក់មូលដ្ឋាន ។

## ៣.១.៥. ការកាត់បន្ថយភាពក្រីក្រ

ទេសចរណ៍ គឺជាកម្លាំងមួយជួយជំរុញកំណើនសេដ្ឋកិច្ចឱ្យបោះជំហានទៅមុខនាំប្រទេសជាតិ និងសង្គមឱ្យចាកផុតពីភាពអន់ថយ និងក្រីក្រ ។ រាជរដ្ឋាភិបាលកម្ពុជា មានគោលនយោបាយកាត់បន្ថយភាពក្រីក្រតាមរយៈវិស័យទេសចរណ៍ដូចខាងក្រោម :

- ក្រសួងទេសចរណ៍ ត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានា ដើម្បីសិក្សាស្វែងយល់បន្ថែមទៀត អំពីទំនាក់ទំនងរវាងការកាត់បន្ថយ

ភាពក្រីក្រ និងការអភិវឌ្ឍទេសចរណ៍នៅក្នុងប្រទេសកម្ពុជា។ កិច្ចការនេះ នឹងតម្រូវឱ្យមានការសិក្សាស្រាវជ្រាវ ដែលមានផែនការច្បាស់លាស់ និងគ្រប់គ្រងល្អ

- រាជរដ្ឋាភិបាល យកចិត្តទុកដាក់ក្នុងការរៀបចំយន្តការគ្រប់គ្រង និងគាំទ្រយ៉ាងពេញទំហឹងដល់ក្រុមការងារទេសចរណ៍ សម្រាប់កាត់បន្ថយភាពក្រីក្រ និងគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍រាជធានី ខេត្តក្រុង សម្រាប់ការពង្រឹងសមត្ថភាព និងកិច្ចប្រតិបត្តិការរបស់ខ្លួន

- ត្រូវបង្កើតជាបន្ទាន់ នូវភាពជាដៃគូសម្រាប់កិច្ចអភិវឌ្ឍសហគ្រាសទេសចរណ៍ធុនតូច និងមធ្យម ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការនានា និងផ្នែកឯកជន ព្រមទាំងផ្តល់នូវគោលនយោបាយលើកទឹកចិត្តឱ្យមានការវិនិយោគគ្រប់ទ្រង់ទ្រាយតូច ធំ មធ្យម នៅតាមសហគមន៍ជនក្រីក្រ។

## ៣.២. កិច្ចសហប្រតិបត្តិការជាមួយវិស័យដទៃទៀត

វិស័យទេសចរណ៍មានលក្ខណៈជាប្រព័ន្ធ ដូច្នេះការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព ទាមទារនូវការចូលរួមយ៉ាងសកម្ម និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួង ស្ថាប័នផ្នែកសាធារណៈ ផ្នែកឯកជន សង្គមស៊ីវិល ។ល។ ជាអាទិ៍ កិច្ចសហប្រតិបត្តិការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល នឹងក្លាយទៅជាសមាសភាគដ៏សំខាន់នៃសកម្មភាពវិស័យទេសចរណ៍ ដោយហេតុថា ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្រាប់ឧស្សាហកម្មទេសចរណ៍មានដូចជា ផ្លូវគមនាគមន៍ ទូរគមនាគមន៍ ព្រលានយន្តហោះ កំពង់ផែ ប្រព័ន្ធអគ្គិសនី ទឹកស្អាត និងប្រព័ន្ធលូ ត្រូវបានផ្តល់ដោយស្ថាប័នទាំងនេះ។ ដោយឡែកកិច្ចសហប្រតិបត្តិការជាមួយក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នឹងត្រូវតែបន្តឱ្យកាន់តែជិតស្និទ្ធថែមទៀត ដោយហេតុថា ធនធានទេសចរណ៍ដូចជា រមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រ ឧទ្យានជាតិ ដែនជម្រកសត្វ តំបន់ការពារធម្មជាតិ ។ល។ ជាទូទៅងាយនឹងទទួលរង

National Tourism of Polic with cover on 19.08.2010:Layout 1 19/08/2010 10:34 Page 12

គ្រោះថ្នាក់ ឬស្ថិតក្រោមការគំរាមគំហែងជាប្រចាំ ។ ដូច្នេះ ទាមទារឱ្យមានកិច្ចសហការរវាងក្រសួងទេសចរណ៍ និងក្រសួង ស្ថាប័ន ផ្នែកសាធារណៈ ផ្នែកឯកជន សង្គមស៊ីវិលទាំងអស់ ក្នុងការគ្រប់គ្រងដោយប្រុងប្រយ័ត្ន មានផែនការសមស្របប្រកបដោយនិរន្តរភាព ដើម្បីកាត់បន្ថយនូវបាតុភាពអសកម្ម និងផលប៉ះពាល់ជាអវិជ្ជមាននានា ។

### ៣.៣. ការអភិវឌ្ឍធនធានមនុស្ស

#### ៣.៣.១. ការអប់រំ និងការបណ្តុះបណ្តាល

ការអប់រំ និងការបណ្តុះបណ្តាល ក្នុងគោលដៅអភិវឌ្ឍធនធានមនុស្សសម្រាប់គ្រប់ផ្នែកនៃឧស្សាហកម្មទេសចរណ៍ ត្រូវបានទទួលស្គាល់ថា ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព ហើយត្រូវបានឧបត្ថម្ភគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា ផ្នែកឯកជន និងដៃគូអភិវឌ្ឍ ។ ក្រសួងទេសចរណ៍ត្រូវគ្រប់គ្រង និងអភិវឌ្ឍការធ្វើបដិសណ្ឋារកិច្ច សណ្ឋាគារ ទេសចរណ៍វប្បធម៌ អេកូទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ប្រព័ន្ធព័ត៌មានទេសចរណ៍ ការីទេសចរណ៍ ភ្នាក់ងារទេសចរណ៍ អាហារដ្ឋាន និងភោជនីយដ្ឋាន ការធ្វើដំណើរ និងដឹកជញ្ជូនទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ កីឡាទេសចរណ៍ ។ល ។

ដើម្បីឆ្លើយតបទៅនឹងការបំពេញគោលបំណងនេះ ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើត :

- វិទ្យាស្ថានជាតិទេសចរណ៍មួយ ដើម្បីសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់នៃវិស័យទេសចរណ៍ ក្នុងគោលបំណងបង្កើតគោលនយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព
- សាកលវិទ្យាល័យជាតិទេសចរណ៍ និងបដិសណ្ឋារកិច្ចមួយ ដើម្បីធ្វើការអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សកម្រិតឧត្តមសិក្សា និងមធ្យមសិក្សាលើគ្រប់ជំនាញ និងគ្រប់កម្រិតនៃវិស័យទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច
- សាលាវិជ្ជាជីវៈទេសចរណ៍មួយ ដើម្បីបណ្តុះបណ្តាល និងអភិវឌ្ឍជំនាញទេសចរណ៍ប្រកបដោយគុណភាព និងស្តង់ដារអន្តរជាតិ ។

### ៣.៣.២. ការសិក្សាស្រាវជ្រាវ និងស្ថិតិទេសចរណ៍

ក្រសួងទេសចរណ៍ ត្រូវខិតខំប្រឹងប្រែងបង្កើនសមត្ថភាពរបស់ខ្លួន ក្នុងការអនុវត្តការងារដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវទេសចរណ៍ និងយកចិត្តទុកដាក់ក្នុងការប្រមូលចងក្រងប្រព័ន្ធស្ថិតិទេសចរណ៍មួយ ប្រកបដោយគុណភាព តម្លាភាព ឆ្លើយតបទាន់សភាពការណ៍ ជាពិសេសការស្រាវជ្រាវទីផ្សារទេសចរណ៍ថ្មីៗ តម្រូវការរបស់ទេសចរជាតិ និងអន្តរជាតិ ដែលទាំងអស់នេះគឺជាសមាសភាគដ៏សំខាន់នៃឧស្សាហកម្មទេសចរណ៍ និងជាត្រីវិស័យ ក្នុងការចងក្រងផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍របស់ជាតិ ។

### ៣.៣.៣. កម្មវិធីផ្សព្វផ្សាយយល់ដឹងសាធារណៈ

ការបន្ថែមលើការអប់រំ និងការបណ្តុះបណ្តាលសម្រាប់វិស័យទេសចរណ៍ ក្រសួងទេសចរណ៍ ត្រូវសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធ ក្នុងការបញ្ចូលកម្មវិធីការយល់ដឹង និងសារៈប្រយោជន៍នៃវិស័យទេសចរណ៍ទៅក្នុងកម្មវិធីសិក្សា ព្រមទាំងបង្កើតកម្មវិធីផ្សព្វផ្សាយយល់ដឹងជាសាធារណៈ ជាបន្តបន្ទាប់ សំដៅឆ្ពោះទៅកាន់ការបំពាក់បំប៉ននូវការយល់ដឹងមួយកម្រិតថែមទៀតនៃវិស័យទេសចរណ៍ ជាអាទិ៍ទេសចរណ៍វប្បធម៌ ទេសចរណ៍ធម្មជាតិ ស្វែងយល់អំពីផលប្រយោជន៍ ផលប៉ះពាល់អវិជ្ជមាន និងដំណោះស្រាយសមស្រប ។

### ៣.៣.៤. ការកសាងសមត្ថភាពរបស់ក្រសួងទេសចរណ៍

ការអភិវឌ្ឍធនធានមនុស្ស និងការកសាងសមត្ថភាពរបស់ក្រសួងទេសចរណ៍ នឹងត្រូវធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពផ្ទៃក្នុង ដើម្បីឆ្លើយតបទៅនឹងការប្រកួតប្រជែងនានា ព្រមទាំងធានាផ្តល់នូវកិច្ចអភិវឌ្ឍឧស្សាហកម្មទេសចរណ៍កម្ពុជាមួយប្រកបដោយនិរន្តរភាព ។ ក្នុងបរិបទនេះ ក្រសួងនឹងធ្វើការអភិវឌ្ឍជំនាញផែនការទេសចរណ៍ ជាក់ស្តែងតាមរយៈការអប់រំជាន់ខ្ពស់ ការបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តម ចំពោះមន្ត្រីបម្រើការងារសំខាន់ៗ កម្មវិធីបណ្តុះបណ្តាលវគ្គបំប៉នខ្លីៗ សម្រាប់មន្ត្រីថ្នាក់ដឹកនាំ ជំរុញការដកស្រង់បទពិសោធពីប្រទេសនានា និងគាំទ្រលើកទឹកចិត្តឱ្យមានការចុះជួយពង្រឹងថ្នាក់មូលដ្ឋានពីសំណាក់មន្ត្រីក្រសួង ។

National Tourism of Polic with cover on 19.08.2010:Layout 1 19/08/2010 10:34 Page 14

## ៣.៤. ផ្នែកឯកជន

### ៣.៤.១. ការទ្រទ្រង់ចំពោះផ្នែកឯកជន

ក្នុងការទទួលស្គាល់តួនាទីដ៏សំខាន់ និងចាំបាច់របស់ផ្នែកឯកជន ក្នុងការអភិវឌ្ឍទេសចរណ៍ និងសមត្ថភាពជំនាញដ៏ប៉ិនប្រសប់ក្នុងការធ្វើធុរកិច្ច រាជរដ្ឋាភិបាលបន្តពង្រឹងការងារផ្នែកច្បាប់ និងការគ្រប់គ្រង ការចងក្រងជាសមាគមទេសចរណ៍ ព្រមទាំងត្រូវដាក់ចេញនូវគោលនយោបាយលើកទឹកចិត្តសមស្រប និងកិច្ចសហការដ៏ស្អិតរមួត ។

ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការវិនិយោគទុន ក្រសួងទេសចរណ៍ មានទិសដៅ និងគោលបំណងជំរុញលើកទឹកចិត្តគាំទ្រដល់ការបណ្តាក់ទុនគ្រប់រូបភាពតូច មធ្យម ធំ ដោយសហគ្រិនក្នុងស្រុក និងជនបរទេសក្នុងទម្រង់នៃការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព ដើម្បីឈានទៅប្រើ ប្រាស់ឱ្យអស់លទ្ធភាពនូវសក្តានុពលទេសចរណ៍របស់ជាតិ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ។

### ៣.៤.២. ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍

ក្រសួងទេសចរណ៍ ត្រូវជំរុញបង្កើនការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ ទាំងក្នុង និងក្រៅប្រទេសតាមគ្រប់មធ្យោបាយ និងគ្រប់បណ្តាញផ្សព្វផ្សាយសមស្រប ។

ការសិក្សាទីផ្សារទេសចរណ៍ ត្រូវធ្វើឡើងក្នុងភាពជាដៃគូ ជាមួយផ្នែកឯកជន ដោយឆ្លងតាមរយៈក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ ដោយត្រូវផ្តោតទៅលើរមណីយដ្ឋានវប្បធម៌ ធម្មជាតិ ប្រវត្តិសាស្ត្រ និងការគោរពនូវតម្លៃនៃប្រពៃណី ទំនៀមទំលាប់របស់ជាតិ ។

ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ ត្រូវខិតខំប្រឹងប្រែងធ្វើឱ្យព្រះរាជាណាចក្រកម្ពុជា ក្លាយជាគោលដៅទេសចរណ៍មួយដែលមានការជ្រើសរើសពីសំណាក់ទេសចរជាតិ និងអន្តរជាតិ ដោយធ្វើការបង្កើតយន្តការផ្សព្វផ្សាយ សមស្របតាមសន្ទុះរីកចម្រើននៃវិស័យទេសចរណ៍ ចូលរួមតាំងពិព័រណ៌ទាំងក្នុង និងក្រៅប្រទេស និងត្រូវទទួលខុសត្រូវនូវរាល់ការផលិត និងបោះពុម្ពផ្សាយឯកសារទេសចរណ៍គ្រប់រូបភាព ។

### ៣.៤.៣. ការធ្វើអាជីវកម្មទេសចរណ៍

ផ្នែកឯកជនត្រូវបានគាំទ្រដោយស្មើភាពគ្នា ក្នុងការធ្វើអាជីវកម្មទេសចរណ៍ នៅក្រោមច្បាប់ជាធរមាន ។

### ៣.៤.៤. ក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈ

ដើម្បីធានានិរន្តរភាពដល់ការធ្វើធុរកិច្ច និងជាការពង្រឹងដល់គោលនយោបាយ ការពារអតិថិជនក្នុងវិស័យទេសចរណ៍ ក្រសួងទេសចរណ៍តម្រូវឱ្យអង្គការ សមាគម និងបណ្ដាអ្នកធ្វើអាជីវកម្មក្នុងវិស័យទេសចរណ៍ទាំងអស់ បង្កើត នូវក្រមសីលធម៌ ក្រមប្រតិបត្តិវិជ្ជាជីវៈ និងលក្ខន្តិកៈ ដោយមានការត្រួតពិនិត្យ ពីក្រសួង និងដាក់ឆ្លងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធរបស់រដ្ឋធ្វើការពិនិត្យ និង អនុម័ត ។

### ៣.៥. ការសម្រួលការធ្វើដំណើរ និងទំនាក់ទំនងអន្តរជាតិ

### ៣.៥.១. ការសម្រួលការធ្វើដំណើរ និងបែបបទចេញ ចូលនៃទេសចរ

កិច្ចសហប្រតិបត្តិការ ត្រូវបន្តធ្វើជាមួយស្ថាប័នសាធារណៈជួរមុខ ដូចជា មន្ត្រី នគរបាល ភ្នាក់ងារគយ និងរដ្ឋាករ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ក្នុងការរៀបចំ បដិសណ្ឋារកិច្ចនៅពេលដែលទេសចរបានចូលមកដល់កម្ពុជា ។ ទន្ទឹមនោះ ការ សម្រួលបែបបទចេញ ចូល ការបង្កើតបន្ថែមច្រកទ្វារព្រំដែន ការសហការជា មួយបណ្ដាប្រទេសជិតខាង និងការបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាង ជូនដល់ទេសចរ គឺជាប្រការចាំបាច់ និងត្រូវយកចិត្តទុកដាក់បំផុត ។

### ៣.៥.២. ទំនាក់ទំនងអាស៊ាន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

ដើម្បីអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា ឱ្យទទួលបាន ជោគជ័យ រាជរដ្ឋាភិបាលបន្តជំរុញកិច្ចសហការជាមួយសមាគមអាស៊ានលើវិស័យ ទេសចរណ៍ ដោយបន្តអនុវត្តឱ្យខ្លាំងក្លានូវកិច្ចព្រមព្រៀងទេសចរណ៍អាស៊ាន ការធ្វើសមាហរណកម្មសេវាកម្មទេសចរណ៍អាស៊ាន ព្រមទាំងជំរុញការអនុវត្ត អនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចសហប្រតិបត្តិការអន្តរជាតិទ្វេភាគី និង ពហុភាគីជាមួយបណ្ដាប្រទេសនានាលើសកលលោក ។ ទន្ទឹមនោះ បន្តខិតខំជំរុញ កិច្ចសហប្រតិបត្តិការជាមួយស្ថាប័ន អង្គការអន្តរជាតិនានាដូចជា អង្គការ ទេសចរណ៍ពិភពលោក អង្គការពាណិជ្ជកម្មពិភពលោក សមាគមទេសចរណ៍ អាស៊ីប៉ាស៊ីហ្វិក ទេសចរណ៍មហាអនុតំបន់ទន្លេមេគង្គ វេទិកាទេសចរណ៍ អាស៊ាន ។ល ។

# សេចក្តីសន្និដ្ឋាន

គោលនយោបាយជាតិលើវិស័យទេសចរណ៍ គឺជាមាគ៌ាមួយសម្រាប់តម្រង់ទិសលើការអភិវឌ្ឍទេសចរណ៍ប្រកបដោយសមធម៌ ប្រសិទ្ធភាពខ្ពស់ និរន្តរភាព ទន្ទឹមនឹងកិច្ចអភិរក្ស ថែរក្សា ការពារឱ្យបានល្អប្រសើរនូវបេតិកភណ្ឌជាតិ កេរដំណែលវប្បធម៌ ប្រវត្តិសាស្ត្រ ប្រពៃណី ទំនៀមទម្លាប់ ប្រភពធនធានធម្មជាតិរបស់ជាតិ សម្រាប់ពេលបច្ចុប្បន្ន ក៏ដូចជាពេលអនាគត ។ គោលនយោបាយនេះ នឹងជួយកែលំអ ព្រមទាំងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ពិសេសប្រជាពលរដ្ឋក្រីក្រ រួមទាំងបងប្អូនជនជាតិភាគតិច ដែលរស់នៅតាមតំបន់គោលដៅទាក់ទាញទេសចរណ៍អាទិភាពទាំងឡាយ និងជាការសម្រេចឱ្យបាននូវផែនការយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ។

គោលនយោបាយជាតិលើវិស័យទេសចរណ៍ ធ្វើឱ្យស្ថាប័នរដ្ឋ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់ស្រទាប់ជាន់ថ្នាក់ កាន់តែយល់ជ្រួតជ្រាបច្បាស់លាស់អំពីសារៈសំខាន់នៃវិស័យទេសចរណ៍ ដែលជាឧស្សាហកម្មដ៏មានសក្តានុពលបំផុតក្នុងការនាំមកនូវប្រភពចំណូលរូបិយប័ណ បង្កើតការងារ ចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ ដើម្បីលើកស្ទួយកំណើនសេដ្ឋកិច្ចជាតិ ព្រមទាំងធ្វើឱ្យមានការចូលរួមយ៉ាងសកម្មក្នុងការថែរក្សា ការពារ អភិរក្ស គ្រប់គ្រង និងប្រើប្រាស់សម្បត្តិវប្បធម៌ និងធនធានធម្មជាតិប្រកបដោយស្មារតីទទួលខុសត្រូវ ប្រសិទ្ធភាពខ្ពស់ និងមាននិរន្តរភាព ។